**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថាស្វាគមន៍ និងសេចក្ដីរាយការណ៍

**ថ្លែងដោយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប អំពីវឌ្ឍនភាពនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

**ជូនចំពោះសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**ក្នុងពិធីផ្សព្វផ្សាយស្ដីពីកិច្ចដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ**

**នៅថ្នាក់ក្រោមជាតិ**

**សាលសន្និសីទចតុមុខ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩**

- សូមគោរព **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ សមាជិក សមាជិកានៃរាជរដ្ឋាភិបាលកម្ពុជា
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- ឯកឧត្តមអភិបាល អភិបាលរងរាជធានី និងខេត្ត
- ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស អធិកអធមនេះ តាងនាមឱ្យគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្នុងនាមអង្គពិធីទាំងមូល ខ្ញុំសូមសម្ដែងនូវគារវកិច្ចយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះវត្តមានដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែល **សម្តេច** បានឆ្លៀតឱកាសដ៏មមាញឹកនៅក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តម ដើម្បីបម្រើជាតិ និងប្រជារាស្ត្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីផ្សព្វផ្សាយស្តីពីកិច្ចដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នាឱកាសដ៏មហោឡារិកអធិកអធមនេះ ។

- **សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

បន្ទាប់ពីប្រទេសកម្ពុជាបានរំដោះរួចផុតពីរបបប្រល័យពូជសាសន៍ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រចនាសម្ព័ន្ធ និងប្រព័ន្ធសេដ្ឋកិច្ចសង្គម និងរដ្ឋបាលសាធារណៈរបស់ជាតិទាំងមូល ត្រូវបានរៀបចំជាថ្មីឡើងវិញ ហើយនឹងបានធ្វើការកែទម្រង់ជាបន្តបន្ទាប់ សម្រាប់ជាមូលដ្ឋាននៃការស្តាបនាជាតិឡើងវិញ ។ បន្ទាប់ពីការបោះឆ្នោតជាតិតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស នាឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីនយោបាយជាបន្តបន្ទាប់ ដើម្បីធ្វើការកែទម្រង់លើគ្រប់វិស័យ រួមទាំងរដ្ឋបាលសាធារណផង សំដៅបន្តស្តាបនាប្រទេសកម្ពុជាឡើងវិញ ។

ក្រោមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី២ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការសិក្សាពិចារណា អំពីការកែទម្រង់អភិបាលកិច្ចមូលដ្ឋានបែបប្រជាធិបតេយ្យតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ចាប់តាំងពីឆ្នាំ១៩៩៩មក ។ គំនិតផ្តួចផ្តើមនេះ បានធ្វើឡើងប្រមាណតែជាងមួយឆ្នាំប៉ុណ្ណោះ បន្ទាប់ពីប្រទេសជាតិទទួលបាននូវសុខសន្តិភាពពេញលេញ មានការឯកភាពទឹកដី ក្រោមនយោបាយ **"ឈ្នះឈ្នះ"** ដែលជាគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតដ៏វៀងវៃរបស់ **សម្តេចនាយករដ្ឋមន្ត្រី** ។ ការសិក្សាពិចារណានេះបានឈានដល់កុងសង់ស៊ុសខាងនយោបាយ ក្នុងការរៀបចំឱ្យមានការបោះឆ្នោតដោយផ្ទាល់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅថ្នាក់ឃុំ សង្កាត់ទូទាំងប្រទេស រួមទាំងឃុំ សង្កាត់ដែលទើបនឹងធ្វើសមាហរណកម្មផង នាខែកុម្ភៈ ឆ្នាំ២០០២ ។ ការបោះឆ្នោតនេះបានបង្កើតឡើងនូវស្ថាប័នអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋានជាលើកដំបូងនៅកម្ពុជា ។

លទ្ធផលនៃការបោះឆ្នោត និងការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ក្នុងអាណត្តិទី១ បានផ្តល់ផលប្រយោជន៍ ដែលជាមេរៀន បទពិសោធន៍ដ៏ចម្បង ៣យ៉ាងក្នុងដំណើរការស្តាបនាប្រទេសកម្ពុជាឡើងវិញ ដែលរួមមាន ÷

__**ទីមួយ**__ : រួមចំណែកដល់ការពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការពង្រឹងស្ថេរភាពនយោបាយនៅកម្ពុជា ។

**ទីពីរ** : រួមចំណែកធ្វើឱ្យប្រសើរឡើងនូវមូលធនសង្គម និងមូលធននយោបាយនៅកម្ពុជា។ មូលធនសង្គម សំដៅទៅលើការរៀបចំឡើងវិញនូវទំនាក់ទំនងរវាងប្រជាជន និងប្រជាជននៅមូលដ្ឋាន លើមូលដ្ឋាននៃភាពគ្មានការរើសអើង អហិង្សា សមធម៌ និងការសហការជួយគ្នាទៅវិញទៅមកក្នុងសហគមមូលដ្ឋាន។ មូលធននយោបាយ គឺជាការធ្វើឱ្យកាន់តែប្រសើរឡើងនូវទំនាក់ទំនងរវាងប្រជាពលរដ្ឋ ជាមួយស្ថាប័នសាធារណៈនានា ក្នុងនោះជាបឋម គឺទំនាក់ទំនងជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងរដ្ឋបាលរបស់ក្រុមប្រឹក្សាទាំងនោះ ប្រកបដោយលក្ខណៈតម្លាភាព មានការឆ្លើយតប និងមានគណនេយ្យភាព។

**ទីបី** : រួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍មូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។

ដើម្បីគាំទ្រ និងតម្រង់ទិសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការឈានឆ្ពោះទៅសម្រេចបាននូវផលប្រយោជន៍ជាមូលដ្ឋានទាំងបីខាងលើនេះ ច្បាប់តម្រូវឱ្យបង្កើតនូវយន្តការសម្របសម្រួលគាំទ្រមួយ គឺ "គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ឃ.ស)"។ ក្នុងរយៈពេលនៃអាណត្តិរបស់ខ្លួន គណៈកម្មាធិការជាតិនេះបានសម្រេចនូវកិច្ចការជាច្រើនក្នុងការសម្របសម្រួល ដើម្បីគាំទ្រដល់ការកែទម្រង់នៅថ្នាក់ឃុំ សង្កាត់។ តាមរយៈការ ប្រឹងប្រែងគាំទ្រនេះ បានបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ដ៏ថ្មីថ្មោង ចាប់ផ្តើមបោះជំហានក្នុងការបំពេញការងាររបស់ខ្លួនជាមួយរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មី សម្រេចបានសមិទ្ធផលជាច្រើន។ គ.ឃ.ស ក៏បាន បញ្ចប់អាណត្តិរបស់ខ្លួនក្នុងរយៈពេល ៩ខែមុនការបោះឆ្នោតឃុំ សង្កាត់លើកទី២ តាមច្បាប់កំណត់។

ផ្អែកតាមបទពិសោធន៍ និងសមិទ្ធផលនៃការកែទម្រង់នៅថ្នាក់ឃុំ សង្កាត់ បានលេចឡើងនូវបញ្ហាប្រឈម ដែលតម្រូវឱ្យមានការកែទម្រង់នៅរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌជាបន្តទៀត។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលបានបង្កើតឡើងនូវគណៈកម្មការអន្តរក្រសួងមួយសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ។ ប៉ុន្តែអាស្រ័យដោយតម្រូវការនៃការបន្តគាំទ្រដល់កំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ រួមទាំងការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការជាតិមួយត្រូវបានបង្កើតឡើង គឺគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) តាមព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ហើយបានបញ្ចប់ការងារកាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ កន្លងទៅនេះ។

ដោយឈរលើបទពិសោធន៍ដែលទទួលបានពី " **ការធ្វើផង រៀនសូត្រផង និងដកពិសោធន៍ផង** "

នៅថ្នាក់ឃុំ សង្កាត់ រួមនឹងការគាំទ្រពីសំណាក់មិត្តភ័ក្រ្តជាដៃគូអភិវឌ្ឍន៍នានារបស់កម្ពុជា នៅខែ មិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ គឺជាមូលដ្ឋានបង្អែកខាងនយោបាយសម្រាប់ការត្រួសត្រាយផ្លូវក្នុងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីបើកផ្លូវដល់ការតាក់តែងច្បាប់សម្រាប់ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ និងបានប្រកាសឱ្យប្រើនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ កន្លងមកនេះ ។ ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាការបំពេញបន្ថែមទៅលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលបានបង្កើតនូវសំណុំក្របខ័ណ្ឌច្បាប់រៀបចំអង្គការមួយ សម្រាប់កសាងនូវប្រព័ន្ធអភិបាលនៅថ្នាក់ក្រោមជាតិ ដែលមានទំនាក់ទំនងផ្សារភ្ជាប់គ្នា និងការគាំទ្រគ្នាទៅវិញទៅមក ដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ។ សំណុំនៃច្បាប់រៀបចំអង្គការនេះបានតម្រូវឱ្យ ÷

- កំណត់អត្តសញ្ញាណ និងការគ្រប់គ្រងតំបន់ប្រជុំជន និងតំបន់ក្រៅពីទីប្រជុំជន ដែលមានលក្ខណៈមិនដូចគ្នា តែមានទំនាក់ទំនង និងការគាំទ្រគ្នាទៅវិញទៅមក សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌ ។
- បង្កើតនូវក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមការបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់ ដែលតម្រូវឱ្យក្រុមប្រឹក្សាទាំងនោះមានមុខងារសំខាន់ៗ ជាមួយការប្រគល់ហិរញ្ញវត្ថុ បុគ្គលិក និងធនធានចាំបាច់ដទៃទៀត សំដៅឆ្លើយតបតម្រូវការនៅមូលដ្ឋាន ។
- បង្កើតនូវរដ្ឋបាលឯកភាពសម្រាប់ក្រុមប្រឹក្សាតាមប្រភេទនីមួយៗ សំដៅលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៅមូលដ្ឋាន ។
- រួមបញ្ចូលនូវវិមជ្ឈការ និងវិសហមជ្ឈការសារពើពន្ធ ដែលជាផ្នែករួមបញ្ចូលគ្នាមិនអាចកាត់ផ្តាច់បានពីដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។
- កំណត់អំពីយន្តការសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈ ដើម្បីលើកកម្ពស់តម្លាភាព ការឆ្លើយតប និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។

ព្រមជាមួយនេះ ច្បាប់រៀបចំអង្គការក៏បានតម្រូវឱ្យបង្កើតនូវយន្តការអនុវត្តមួយ ដើម្បីសម្របសម្រួលអនុវត្តច្បាប់ និងការពិនិត្យមើលឡើងវិញនូវមុខងារ និងការទទួលខុសត្រូវ សំដៅរៀបចំផ្ទេរជាជំហានៗដល់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមជាមួយការផ្ទេរហិរញ្ញវត្ថុ ធនធាន ទ្រព្យសម្បត្តិ បុគ្គលិក និងសមត្ថភាពផង ។

ដោយសារកំណែទម្រង់នេះមានភាពស៊ាំញ៉ាំ ត្រូវការនូវពេលវេលា ហើយនឹងភាពចាំបាច់នៃការពិគ្រោះពិភាក្សា ស្រុះស្រួលគ្នានៅក្នុងផ្ទៃក្នុងជាតិ សំដៅធានាបាននូវការប្តេជ្ញាចិត្តខាងនយោបាយរយៈពេលវែង ច្បាប់រៀបចំអង្គការបានតម្រូវឱ្យបង្កើតនូវ " គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) " ដែលមានអាណត្តិជាអចិន្ត្រៃយ៍ និងមានរចនាសម្ព័ន្ធតួនាទី មុខងារសមស្រប ក្នុងការសម្របសម្រួលអនុវត្តច្បាប់រៀបចំអង្គការ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

ផ្អែកតាមស្មារតីនេះ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.អ.ប ត្រូវបានសម្រេចដោយព្រះរាជក្រឹត្យលេខ សន/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ កន្លងទៅនេះ ។ សម្រាប់ជាការចាប់ផ្តើមដំណើរការរបស់ខ្លួន គ.ជ.អ.ប បានបើកកិច្ចប្រជុំលើកទី១ ដើម្បីពិភាក្សា និងអនុម័តបទបញ្ជាផ្ទៃក្នុង ការអនុម័តលើប្រតិទិនការងារពីនេះរហូតដល់ដំណាច់ឆ្នាំ២០០៩ និងពិភាក្សាអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការជាជំនួយការ និងលេខាធិការដ្ឋានរបស់ខ្លួន រួមទាំងការពិនិត្យមើលកិច្ចការដែលត្រូវអនុវត្តបន្តពី គ.ជ.វ.វ ផង ។ គ.ជ.អ.ប មានសមាជិកចំនួន ១៦រូប មកពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន១៣ នៃរាជរដ្ឋាភិបាលកម្ពុជា។ គ.ជ.អ.ប មានអនុគណៈកម្មាធិការចំនួន៤ គឺអនុគណៈកម្មាធិការមុខងារ និងធនធាន អនុគណៈកម្មាធិការកិច្ចការសារពើពន្ធ និងហិរញ្ញវត្ថុ អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ និងមានលេខាធិការដ្ឋានស្ថិតក្នុងទីស្តីការក្រសួងមហាផ្ទៃ ។

- **សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ដើម្បីអនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានប្រកាសយកថ្ងៃអាទិត្យទី១៧ ខែឧសភា ឆ្នាំ២០០៩ ខាងមុខនេះ ជាកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលទាំងនេះ ស្របតាមការកំណត់នៃច្បាប់ ។ លើមូលដ្ឋាននេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏បានដាក់ចេញនូវប្រតិទិនការងារបោះឆ្នោតនេះ រួមទាំងការត្រៀមរៀបចំកិច្ចការនានា សំដៅធានាឱ្យការបោះឆ្នោតនេះមានលក្ខណៈបើកចំហរ សេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

រហូតមកទល់ពេលនេះ មានកិច្ចការជាច្រើនដែលបាននឹងកំពុងរៀបចំ ដើម្បីអនុវត្តច្បាប់នេះ ក្នុងនោះមានកិច្ចការសំខាន់ៗ ជាអាទិ៍ ៖

- កំពុងរៀបចំតាក់តែងកម្មវិធីជាតិមួយមានរយៈពេល ១០ឆ្នាំសម្រាប់អនុវត្តច្បាប់ ដែលគ្រោង

នឹងបញ្ចប់ការតាក់តែងនៅចុងឆមាសទី១ ឆ្នាំ២០០៩ នេះ ។

- រៀបចំតាក់តែងលិខិតបទដ្ឋានចាំបាច់មួយចំនួនមុនការបោះឆ្នោត រួមទាំងការបណ្តុះបណ្តាល ការអប់រំសាធារណជន ក្នុងដំណាក់កាលមុន និងក្រោយការបោះឆ្នោត ។
- សម្រេចប្តូរប្រភេទរដ្ឋបាលមួយចំនួននៅថ្នាក់ក្រោមជាតិ ស្របតាមស្មារតីនៃច្បាប់រៀបចំអង្គការ ។
- បានប្រកាសចំនួនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ការបោះឆ្នោតលើកទី១ នេះ ។
- ការបន្តគាំទ្រដល់កំណែទម្រង់នៅរដ្ឋបាលឃុំ សង្កាត់ឱ្យដំណើរការជាប្រក្រតីក្នុងដំណាក់កាលនៃការត្រៀមរៀបចំបោះឆ្នោតនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ក្នុងឱកាសដ៏មហោឡារិក អធិក អធមនេះ ក្នុងនាមសមាជិក សមាជិកនៃ គ.ជ.អ.ប និងអង្គពិធីទាំងមូល យើងខ្ញុំសូមគោរពអញ្ជើញ **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាមានមតិសំណេះសំណាល និងផ្តល់អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ដើម្បីជាពុទ្ធិ ដល់យើងខ្ញុំទាំងអស់គ្នាក្នុងការបន្តអនុវត្តនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ សំដៅរួមចំណែកអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដូចដែល **សម្តេចនាយករដ្ឋមន្ត្រី** បានប្រកាសនៅក្នុងកិច្ចប្រជុំទី១ របស់គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ជាថ្មីម្តងទៀតក្នុងនាម គ.ជ.អ.ប ក្នុងនាមសមាជិក សមាជិកានៃអង្គពិធីទាំងមូល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ យើងទាំងអស់គ្នាសូមប្រសិទ្ធពរជ័យមហាប្រសើរ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សូមសម្តេចមានសុខភាពល្អបរិបូរណ៍ និងទទួលបានជោ គជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ **សម្តេច** ក្នុងការបម្រើជាតិ និងប្រជាជនកម្ពុជា ។

**សូមគោរពអញ្ជើញសម្តេចមានមតិសំណេះសំណាលផ្តាំផ្ញើ !**

**សូមគោរពអញ្ជើញ !**